ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ៣៣៣ ចុះថ្ងៃទី ១៧

ខែ ឧសភា ឆ្នាំ ២០០៥

<u>សាលក្រម</u>

លេខ ៣២ ក ចុះថ្ងៃទី ១០

ខែ កុម្ភៈ ឆ្នាំ ២០០៦

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

<u>ចៅក្រមជំនុំជំរះ</u>

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

<u>តំណាងអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញារង

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៣៣៣ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ **ម សម** ហៅ **៩** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីជាងតុទូ មានទីកន្លែងកំណើតនៅភូមិព្រៃកទ័ល ឃុំសសរស្តំ ស្រុកពោធិទ្រា ខេត្តសៀមរាប មានកំរិតវប្បធម៌ថ្នាក់ទី ៥ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិអ៊ូរតាពុក សង្កាត់ទូលល្វា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន មានប្រពន្ធឈ្មោះ **ស** ( លែងលះគ្នា) មានឪពុកឈ្មោះ **អ ឃ** ( ស) មានម្តាយឈ្មោះ **អ អ** ( រ) ទោសពីមុន *គ្មាន* ។

ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៥ នៅចំណុចភូមិវត្ត សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ហើយត្រូវបានឃុំខ្លួនតាមដីកាលេខ ១៦៨ ដឃខ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ នៅអាគារឃុំខ្លួននៃពន្ធនាគារខេត្តបាត់ដំបង ។

ត្រូវចោទពីបទ ប្លន់ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។ ប្រព្រឹត្តនៅភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ។

<u>ជនរងគ្រោះ</u>

-ឈ្មោះ **ឃ ៩** ភេទប្រុស អាយុ ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលជាតិ ទីលំនៅភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ឈ្មោះ **ម សម** បានគាស់សោទ្វារឈ្មោះ

យ ថ ពេលគាស់ហើយឈ្មោះ សម ក៏ចូលលួចយករូបចម្លាក់តែម្តង ឯឈ្មោះ ជ ជាអ្នកចាំផ្លូវ ។

-តាមរបាយការណ៍លេខ ០៧/០៥ រ.ប.ក ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៥ របស់នគរបាលព្រហ្មទណ្ឌកិរិតស្រាលក្រុងប៉ៃលិន បានបញ្ជាក់ថា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ វេលាម៉ោង ១៣ ឈ្មោះ ម សម បានធ្វើសកម្មភាពគាស់ផ្ទះរបស់ឈ្មោះ យ ជ លួចយករូបចម្លាក់ពីរផ្ទាំង យកទៅលក់អោយឈ្មោះ អ ស ក្រោយពីដកហូតវត្ថុតាងរួចកម្លាំងរបស់ការិយាល័យព្រហ្មទណ្ឌ ក៏បានចុះឃាត់ខ្លួនមុខសញ្ញាឈ្មោះ ម សម តែម្តង ។

## នៅចំពោះមុខនាពេលសវនាការ

-ឈ្មោះ ម សម ហៅ ជ ជាជនជាប់ចោទបានឆ្លើយថា ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ខ្លួនពិតជាបានចូលគាស់ទ្វារផ្ទះឈ្មោះ យ ជ លួចយករូបចម្លាក់ពិតប្រាកដមែន ។ ខ្លួនចូលលួចនោះតែម្នាក់ឯង មិនមានបក្សពួកទេ ។ រូបចម្លាក់នេះខ្លួនយកទៅលក់អោយរោងសិប្បកម្មមួយបានប្រាក់ ៤.០០០បាត ទេ ។

-តាមការអានចម្លើយឈ្មោះ យ ថ ជាជនរងគ្រោះបានឆ្លើយថា ( មើលឯកសារលេខ ០២ )

-តាមការអានចម្លើយឈ្មោះ អ ស ជាសាក្សីបានឆ្លើយថា ( មើលឯកសារលេខ ២២ ) ។

## តំណាងអយ្យការធ្វើសន្និដ្ឋានថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ម សម ហៅ ជ ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ស្នើសុំតម្កល់បទចោទទុកជាបានការពេញទាំងមូល និង សុំអោយតុលាការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី ០៥ឆ្នាំ ដល់ ០៧ឆ្នាំ ពីបទចោទ ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ក្រឡាបញ្ជីអានចម្លើយអោយការរបស់ជនរងគ្រោះ ចម្លើយសាក្សី

-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់

-បានពិនិត្យ កំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

-ពិតជាកើតមាននូវអំពើប្លន់ "ចោរកម្មមានគ្នាច្រើននាក់" នៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើប្លន់ដែលកើតនៅកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ ម សម និង ឈ្មោះ ជ ប្រាកដមែន ។

-អំពើដែលជនជាប់ចោទបានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់

ជាបទប្លន់ ដូចមានបញ្ញត្តិក្នុងមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ជនជាប់ចោទ និង ឈ្មោះ ជ ជាសមគ្គជនមានស្មារតីជានាល្អ បានសមគំនិតគ្នាក្នុងតួនាទីជាសហចារីប្រព្រឹត្តបទល្មើស ដោយចេតនា លបលួចយករូបចម្លាក់ធ្វើពីឈើបេងចំនួន ០២ផ្ទាំង ដែលជាទ្រព្យសម្បត្តិរបស់ឈ្មោះ ឃ ឌ ដោយចូលទៅក្នុងផ្ទះលួចយកបានហើយ ដឹកយកទៅចាត់ចែងលក់អោយឈ្មោះ អ ស បានថ្លៃ ចំនួន ៤.០០០បាតយកទៅបំរើផលប្រយោជន៍សួនតួបុគ្គលខ្លួន និង បក្សពួកខ្លួនបានសំរេច ដោយបាន លក់រួចរាល់ និង ចែកប្រាក់គ្នាចាយវាយអស់ ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទពីបទប្លន់ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការ ចោទប្រកាន់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយដោះសាររបស់ជនជាប់ចោទថា ខ្លួនពិតជាបានចូលលួចយករូបចម្លាក់ ធ្វើពីឈើចំនួន ០២ផ្ទាំងពីផ្ទះ របស់ឈ្មោះ ឃ ឌ ជាមួយឈ្មោះ ជ ក្រោយលួចបានអោយឈ្មោះ ជ យកទៅលក់អោយឈ្មោះ អ ស បានថ្លៃ ៤.០០០បាត ចម្លើយនេះស៊ីសង្វាក់គ្នាទៅនឹងចម្លើយអោយការណ៍របស់ជនរងគ្រោះ ចម្លើយឱ្យ ការណ៍របស់សាក្សីឈ្មោះ អ ស វត្ថុតាងដែលរឹបអូសបានពីផ្ទះរបស់ឈ្មោះ អ ស និង ហេតុការណ៍កាលៈ ទេសៈនៃបទល្មើស ។

-ចម្លើយអោយការណ៍របស់ជនរងគ្រោះឈ្មោះ ឃ ឌ បានឆ្លើយអោយការណ៍យ៉ាងច្បាស់លាស់ថា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ខ្លួនបានបាត់ទ្រព្យសម្បត្តិ ដោយត្រូវចោរលួចយកមានរូបចម្លាក់ធ្វើពី ឈើបេងចំនួន ០២ផ្ទាំងមួយផ្ទាំងជារូបចម្លាក់សត្វឥន្ទ្រីយ៍ រូបចម្លាក់ ០១ផ្ទាំងទៀតជាចម្លាក់មនុស្សកាន់ដាវ នៅដៃ និង កាន់ឈើច្រត់ក្រោយពេលដឹងថា ចោរលួចបាត់ខ្លួនក៏សាកសួរអ្នកជិតខាងឈ្មោះ ឍ បាន ប្រាប់ខ្លួនថា គាត់បានឃើញឈ្មោះ សម ហៅ ជ បានយករូបចម្លាក់ចំនួន ០២ផ្ទាំងមានចម្លាក់រូបឥន្ទ្រីយ៍ និង រូបមនុស្សធ្វើពីឈើបេង លាបសាឡិចភ្លឺរលោងយកមកទុកក្បែផ្ទះរបស់គាត់ (ឍ) ចម្លើយនេះវាស៊ី សង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ និង ហេតុការណ៍កាលៈទេសៈនៃបទល្មើស ។

-ចម្លើយអោយការណ៍របស់សាក្សីឈ្មោះ អ ស បានឆ្លើយអោយការណ៍ថា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ខ្លួនបានឃើញឈ្មោះ ម សម ហៅ ជ និង ដៃគូម្នាក់ទៀត បានយករូបចម្លាក់ ០២ផ្ទាំង ដែលមួយផ្ទាំងរូបចម្លាក់សត្វឥន្ទ្រីយ៍ចាប់សត្វឈ្លូស និង មួយផ្ទាំងរូបមនុស្សឈរកាន់ឈើច្រត់ធ្វើពីឈើបេង មកបញ្ចាំឱ្យខ្លួនយកប្រាក់ចំនួន ៤.០០០បាត ។ ក្រោយនគរបាលចាប់ខ្លួនឈ្មោះ ម សម បាននគរបាល បាននាំឈ្មោះ សម ទៅចង្អុលបង្ហាញរួចសមត្ថកិច្ចក៏បានដកហូតយករូបចម្លាក់នោះទៅវិញ ។

-កំណត់ហេតុដកហូតវត្ថុតាងគឺ រូបចម្លាក់ទាំង ០២ផ្ទាំង ពីផ្ទះរបស់ឈ្មោះ អ ស ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ។

-កំណត់ហេតុប្រគល់ទទួលវត្ថុតាងអោយទៅឈ្មោះ ឃ ឌ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានាធ្វើឡើងដោយនគរបាលយុត្តិធម៌ ក្នុងនោះមានកំណត់ហេតុសួរយក ចម្លើយពីឈ្មោះ ម សម ០២លើក និង កំណត់ហេតុដកហូត និង ប្រគល់ទទួលវត្ថុតាង ។

## <u>យល់ឃើញថា</u>

-ជនជាប់ចោទជាជនមានកិរិតវប្បធម៌ទាប គាត់មានជីវភាពក្រខ្សត់ ទើបគេលូកដៃប្រព្រឹត្តបទល្មើស ស្ថានភាពទាំងនេះអាចអោយតុលាការយកមកពិចារណាជាស្ថានសម្រាលទោសអោយគាត់បាន ។

-ឈ្មោះ **ម សប** បានប្រព្រឹត្តបទល្មើសច្រើនលើកច្រើនសារ (ឯកសារលេខរៀង៥.១១) ម្យ៉ាងទៀត គាត់បានកាច់ខ្នោះដៃ មួលផ្តាច់ច្រវ៉ាក់ខ្នោះដៃរត់គេចខ្លួននៅពេលចាប់ដាក់ខ្នោះគាត់លើកទីមួយ ជាហេតុ តុលាការយកមកពិចារណាជាស្ថានទម្ងន់ទោសក្នុងការសំរេចពីទណ្ឌកម្ម ។

## <u>ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ **ម សប** ហៅ **ឌ** ដាក់ពន្ធនាគារកំណត់ ០៦( ប្រាំមួយ) ឆ្នាំគត់ ដោយគិតចាប់ពីថ្ងៃឃុំ ខ្លួនថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ ។

ពីបទ **ប្លន់** " ចោរកម្មមានគ្នាច្រើននាក់ " ប្រព្រឹត្តនៅភូមិបរតាំងស៊ូ សង្កាត់បរយ៉ាខា ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ។

ពីបទព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃ បទឧក្រិដ្ឋ ដែលបានអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

២-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| [redacted] | [redacted] |

---

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រមអោយសំរេច តាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរត្រឹម ត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]